ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

No. ១៩៦ MEF/............

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែមេសា ឆ្នាំ ២០០៣

# ប្រកាស
## ស្តីពី
## ការបោះផ្សាយបំណុលរតនាគារគណនីចរន្តលើកទី២ និងវាបន្តបន្ទាប់ សំរាប់ឆ្នាំ ២០០៣

*****************

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ:០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : ១០ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ២០០០ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ : នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣ ដែលប្រកាស អោយប្រើដោយព្រះរាជក្រមលេខ នស/រកម /១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ : ៨៦ សសរ ចុះ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ

- បានឃើញអនុក្រឹត្យលេខ : ០៨ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៧ ស្តីពីការដាក់ផ្សាយប័ណ្ណរតនាគារ
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ : ០៨ សសរ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការកែសំរួលសមាសភាពគណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ
- តាមសំណើរបស់ គណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយប័ណ្ណរតនាគារ ។

## សំរេច

**ប្រការ ១** : អនុញ្ញាតិអោយរតនាគារជាតិ ចេញផ្សាយលើកទី ២ និង ជាបន្តបន្ទាប់សំរាប់ឆ្នាំ ២០០៣ នូវប័ណ្ណរតនាគារគណនីចរន្តជាប្រាក់រៀល មួយខែម្តង ជារៀងរាល់ខែ មានចំនួនទឹកប្រាក់ ១៦.០០០.០០០.០០០ រៀល ( ដប់ប្រាំមួយពាន់លានរៀល ) ។

**ប្រការ ២** : ប័ណ្ណរតនាគារគណនីចរន្ត ត្រូវបោះផ្សាយដោយរតនាគារជាតិតាមរយៈការដេញថ្លៃបន្តបន្ទាប់ ឬ ផ្សេងពីនេះរហូតដល់កំរិតអតិបរិមាមានទឹកប្រាក់ចំនួន " ៥០ ពាន់លានរៀល " ។

**ប្រការ ៣** : មានតែធនាគារពាណិជ្ជ ឬ អន្តរការីហិរញ្ញវត្ថុប៉ុណ្ណោះ ទើបអាចចុះឈ្មោះជាវប័ណ្ណរតនាគារគណនីចរន្តបាន សំរាប់គណនីរបស់ខ្លួន ឬសំរាប់គណនីរបស់អតិថិជនខ្លួន ។

**ប្រការ ៤** : កាលបរិច្ឆេទនៃការដេញថ្លៃ ទឹកប្រាក់ត្រូវបោះផ្សាយ កាលវសាននិងកាលបរិច្ឆេទត្រូវទូទាត់ប័ណ្ណដែលដេញថ្លៃបាន ត្រូវកំណត់ដោយរតនាគារជាតិ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយគណៈកម្មការចំរុះអន្តរក្រសួង ។

**ប្រការ ៥** : ធនាគារជាតិនៃកម្ពុជា ជាអ្នកទទួលបន្ទុករៀបចំសម័យប្រជុំដេញថ្លៃ ។

**ប្រការ ៦** : បែបបទនៃការដេញថ្លៃ ត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងរវាងធនាគារជាតិនៃកម្ពុជា ជាមួយអ្នកមានសិទ្ធចុះឈ្មោះជាវប័ណ្ណ ឬ ជាមួយអ្នកទទួលសិទ្ធប្រទាន ដែលធនាគារជាតិនៃកម្ពុជាទទួលស្គាល់ជាផ្លូវការ ។

**ប្រការ ៧** : លក្ខខ័ណ្ឌនៃការចេញផ្សាយប័ណ្ណរតនាគារ គណនីចរន្តលើកទី ២ និងជាបន្តបន្ទាប់សំរាប់ឆ្នាំ២០០៣ ត្រូវបានកំណត់ដូចតទៅនេះ :

១- ទឹកប្រាក់នៃប័ណ្ណរតនាគារគណនីចរន្តនិមួយ ៗ ត្រូវមានតំលៃស្មើ " ម្ភៃលានរៀល " ( ២០.០០០.០០០ រៀល ) ។

២- អត្រាការប្រាក់ដែលកំណត់ដោយការដេញថ្លៃ គឺជាអត្រាអប្បហារទូទាត់មុន ។

៣- អាយុកាលនៃប័ណ្ណរតនាគារគណនីចរន្ត គឺ ១៣ សប្តាហ៍ ( ៩១ ថ្ងៃ) ។

៤- ប័ណ្ណរតនាគារត្រូវបានកត់ត្រាបញ្ចូលក្នុងគណនីចរន្តរបស់បរិវិសករ ហើយអាចដូញដូរបានតាមការស្រុះស្រួលព្រមព្រៀងគ្នា ។

៥- តាមរយៈការបង្វែរប័ណ្ណរតនាគារអាចត្រូវបានធ្វើអនុប្បទាន ឬ ដាក់ជាប៉ង់ស្យុង ឬ ដាក់ធានា ។

៦- ប័ណ្ណរតនាគារត្រូវសងវិញនៅថ្ងៃកាលវសាន តាមតំលៃនាមចារឹក

**ប្រការ ៨** : ធនាគារជាតិនៃកម្ពុជា ទទួលភារៈគ្រប់គ្រងគណនីចរន្តប័ណ្ណរតនាគារ និង ជាពិសេសចាត់ចែងកិច្ច ដំណើរការនៃប្រតិបត្តិការនិមួយៗ ដែលពាក់ព័ន្ធទៅនឹងគណនីចរន្តទាំងនោះ ។

**ប្រការ ៩** : បែបបទនៃកិច្ចដំណើរការគណនីចរន្ត ត្រូវបានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងរវាងធនាគារជាតិនៃកម្ពុជា និង ម្ចាស់គណនីចរន្ត ។

**ប្រការ១០**: គណៈកម្មការចំរុះអន្តរក្រសួងរៀបចំបោះផ្សាយប័ណ្ណរតនាគារ រតនាគារជាតិមានភារកិច្ចអនុវត្តប្រកាស នេះ ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាព្រឹទ្ធសភា
- អគ្គលេខារដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- គណៈកម្មការចំរុះអន្តរក្រសួងរៀបចំដាក់ផ្សាយ
  ប័ណ្ណរតនាគារ
- ធនាគារជាតិ នៃកម្ពុជា
- រតនាគារជាតិ
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ